សង្ខិត្តំ ។ ... នសមនន្តរេ ចត្តារិ នអញ្ញមញ្ញេ ទ្វេ នឧបនិស្សយេ ចត្តារិ ។ សង្ខិត្តំ ។ ... នមគ្គេ ចត្តារិ នសម្បយុត្តេ ទ្វេ នវិប្បយុត្តេ ចត្តារិ នោនត្ថិយា ចត្តារិ នោវិគតេ ចត្តារិ ។

(១៩២) នហេតុប្បច្ចយា អារម្មណេ នវ ... អធិបតិយា នវ ។ អនុលោមមាតិកា វិត្ថារេតព្វា ។ ... អវិគតេ នវ ។

នីវរណទុកំ និដ្ឋិតំ ។

# នីវរណិយទុកំ

## បដិច្ចវារោ

(១៩៣) នីវរណិយំ ធម្មំ បដិច្ច នីវរណិយោ ធម្មោ ឧប្បជ្ជតិ ... ។ នីវរណិយទុកំ យថា លោកិយទុកំ ឯវំ កាតព្វំ និន្នានាករណំ ។

ទ្វិក្ខត្តុំ កាមច្ឆន្ទេន ចតុក្ខត្តុំ បដិឃេន ច
ឧទ្ធច្ចំ វិចិកិច្ឆា ច ឧភោចេតេ សកិំ សកិំ
នីវរណានំ នីវរណេហិ អដ្ឋវិធំ បយោជនំ ។
នីវរណទុកស្ស មាតិកា ឥធ កាតា ។

នីវរណិយទុកំ និដ្ឋិតំ ។

សេចក្ដីបំប្រួញ ។ ... កុសលនសមនន្តរប្បច្ច័យ មាន៦រៈ ៤ កុសលន-អញ្ញមញ្ញប្បច្ច័យ មាន៦រៈ ២ កុសលនឧបនិស្សយប្បច្ច័យ មាន៦រៈ ៤ ។ សេចក្ដីបំប្រួញ ។ ... កុសលនមគ្គប្បច្ច័យ មាន៦រៈ ៤ កុសលនសម្បយុត្ត-ប្បច្ច័យ មាន៦រៈ ២ កុសលនវិប្បយុត្តប្បច្ច័យ មាន៦រៈ ៤ កុសលនោនត្ថិ-ប្បច្ច័យ មាន៦រៈ ៤ កុសលនោវិគតប្បច្ច័យ មាន៦រៈ ៤ ។

( ១៩២ ) កុសលអារម្មណប្បច្ច័យ មាន៦រៈ ៩ ព្រោះនហេតុប្ប-ច្ច័យ ... កុសលអធិបតិប្បច្ច័យ មាន៦រៈ ៩ ។ អនុលោមមាតិកា បណ្ឌិត គប្បីឲ្យពិស្ដារចុះ ។ ... កុសលអវិគតប្បច្ច័យ មាន៦រៈ ៩ ។

ចប់ នីវរណទុកៈ ។

# នីវរណិយទុកៈ

## បដិច្ចវារៈ

( ១៩៣ ) នីវរណិយធម៌ អាស្រ័យ នូវនីវរណិយធម៌ ទើបកើតឡើង ... ។ នីវរណិយទុកៈ យ៉ាងណា លោកិយទុកៈ បណ្ឌិត គប្បីធ្វើ យ៉ាងនោះចុះ មិនមានការធ្វើផ្សេងគ្នាឡើយ ។

ការប្រកបដោយកាមច្ឆន្ទៈពីរលើក ការប្រកបដោយបដិឃៈ បួនលើក ឧទ្ធច្ចៈ ១ វិចិកិច្ឆា ១ ទាំងពីរនុ៎ះ មានការប្រកបមួយលើក ។ ការប្រកបនូវពួកនីវរណៈដោយពួកនីវរណៈ មានប្រការ ៨ (យ៉ាងនេះឯង) ។

មាតិកានៃនីវរណទុកៈ លោកបានធ្វើទុក កុសលទីនេះ ។

ចប់ នីវរណិយទុកៈ ។

# នីវរណសម្បយុត្តទុកំ

## បដិច្ចវារោ

(១៩៤) នីវរណសម្បយុត្តំ ធម្មំ បដិច្ច នីវរណសម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នីវរណសម្បយុត្តំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... ។ នីវរណសម្បយុត្តំ ធម្មំ បដិច្ច នីវរណវិប្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នីវរណសម្បយុត្តេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ នីវរណសម្បយុត្តំ ធម្មំ បដិច្ច នីវរណសម្បយុត្តោ ច នីវរណវិប្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា នីវរណសម្បយុត្តំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ ... ។ នីវរណវិប្បយុត្តំ ធម្មំ បដិច្ច នីវរណវិប្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នីវរណវិប្បយុត្តំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ ... បដិសន្ធិ យាវ អជ្ឈត្តិកា មហាភូតា ។ នីវរណសម្បយុត្តញ្ច នីវរណវិប្បយុត្តញ្ច ធម្មំ បដិច្ច នីវរណវិប្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នីវរណសម្បយុត្តេ ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ សង្ខិត្តំ ។

# នីវរណសម្បយុត្តទុកៈ

## បដិច្ចវារៈ

[ ១៩៤ ] នីវរណសម្បយុត្តធម៌ អាស្រ័យ នូវនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវខន្ធ ១ ជានីវរណសម្បយុត្ត នូវខន្ធ ២ ... ។ នីវរណវិប្បយុត្តធម៌ អាស្រ័យ នូវនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកនីវរណសម្បយុត្តកខន្ធ ។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី អាស្រ័យ នូវនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវខន្ធ ១ ជានីវរណសម្បយុត្តផង នូវចិត្តសមុដ្ឋានរូបផង នូវខន្ធ ២ ... ។ នីវរណវិប្បយុត្តធម៌ អាស្រ័យ នូវនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យ នូវខន្ធ ១ ជានីវរណវិប្បយុត្ត នូវខន្ធ ២ ... បដិសន្ធិ មានដរាប ដល់ពួកមហាភូតខាងក្នុង ។ នីវរណវិប្បយុត្តធម៌ អាស្រ័យ នូវនីវរណសម្បយុត្តធម៌ផង នូវនីវរណវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកនីវរណសម្បយុត្តកខន្ធផង នូវពួកមហាភូតផង ។ សេចក្តីបំប្រួញ ។

នីវរណសម្បយុត្តទុកេ បដិច្ចវារោ

(១៩៥) ហេតុយា បញ្ច អារម្មណេ ទ្វេ អធិបតិយា បញ្ច នត្ថិយា ទ្វេ វិគតេ ទ្វេ អវិគតេ បញ្ច ។

(១៩៦) នីវរណសម្បយុត្តំ ធម្មំ បដិច្ច នីវរណសម្បយុត្តោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ បដិច្ច អវិជ្ជានីវរណំ ។ នីវរណវិប្បយុត្តំ ធម្មំ បដិច្ច នីវរណវិប្បយុត្តោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អហេតុកំ នីវរណវិប្បយុត្តំ ... យាវ អសញ្ញសត្តា ។ សង្ខិត្តំ ។

(១៩៧) នហេតុយា ទ្វេ នអារម្មណេ តីណិ នអធិបតិយា បញ្ច នអនន្តរេ បញ្ច នសមនន្តរេ បញ្ច នអញ្ញមញ្ញេ បញ្ច នឧបនិស្សយេ តីណិ នបុរេជាតេ ចត្តារិ នបច្ឆាជាតេ បញ្ច នអាសេវនេ បញ្ច នកម្មេ ទ្វេ នវិបាកេ បញ្ច នអាហារេ ឯកំ នឥន្ទ្រិយេ ឯកំ នឈានេ ឯកំ នមគ្គេ ឯកំ នសម្បយុត្តេ តីណិ នវិប្បយុត្តេ ទ្វេ នោនត្ថិយា តីណិ នោវិគតេ តីណិ ។

## នីវរណសម្បយុត្តទុកៈ បដិច្ចវារៈ

[ ១៩៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងនត្ថិប្បច្ច័យ មានវារៈ ២ ក្នុងវិគតប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៤ ។

[ ១៩៦ ] នីវរណសម្បយុត្តធម៌ អាស្រ័យ នូវនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ អវិជ្ជានីវរណៈ អាស្រ័យ នូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ នីវរណវិប្បយុត្តធម៌ អាស្រ័យ នូវនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ជានីវរណវិប្បយុត្ត ជាអហេតុកៈ ... ដរាបដល់ពួកអសញ្ញសត្វ ។ សេចក្ដីបំប្រួញ ។

[ ១៩៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៤ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៤ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៤ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

(១៩៨) ហេតុប្បច្ចយា នអារម្មណេ តីណិ ... នអធិបតិយា បញ្ច នបុរេជាតេ ចត្តារិ នកម្មេ ទ្វេ នវិបាកេ បញ្ច នសម្បយុត្តេ តីណិ នវិប្បយុត្តេ ទ្វេ នោនត្ថិយា តីណិ នោវិគតេ តីណិ ។

(១៩៩) នហេតុប្បច្ចយា អារម្មណេ ទ្វេ ។ បេ ។ ... មគ្គេ ឯកំ ។ បេ ។ .. អវិគតេ ទ្វេ ។

សហជាតវារោបិ ឯកំ កាតព្វោ ។

## បច្ចយវារោ

(២០០) នីវរណសម្បយុត្តំ ធម្មំ បច្ចយា នីវរណ-សម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ នីវរណវិប្បយុត្តំ ធម្មំ បច្ចយា នីវរណវិប្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នីវរណវិប្បយុត្តំ ឯកំ ខន្ធំ បច្ចយា តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ ... បដិសន្ធិ ឯកំ មហាភូតំ វត្ថុំ បច្ចយា នីវរណ-វិប្បយុត្តា ខន្ធា ។ នីវរណវិប្បយុត្តំ ធម្មំ បច្ចយា នីវរណសម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា

[ ១៩៨ ] កុសលនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... កុសលនអធិបតិប្បច្ច័យ មានវារៈ ៥ កុសលនបុរេជាតប្បច្ច័យ មានវារៈ ៤ កុសលនកម្មប្បច្ច័យ មានវារៈ ២ កុសលនវិបាកប្បច្ច័យ មានវារៈ ៥ កុសលនសម្បយុត្តប្បច្ច័យ មានវារៈ ៣ កុសលនវិប្បយុត្តប្បច្ច័យ មានវារៈ ២ កុសលនោនត្ថិប្បច្ច័យ មានវារៈ ៣ កុសលនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៩៩ ] កុសលអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។ បេ ។ ... កុសលនមគ្គប្បច្ច័យ មានវារៈ ១ ។ បេ ។ ... កុសលអវិគតប្បច្ច័យ មានវារៈ ២ ។

ឯសហជាតវារៈ បណ្ឌិត ត្រូវធ្វើឲ្យជាវារៈ ១ ចុះ ។

## បច្ចយវារៈ

[ ២០០ ] នីវរណសម្បយុត្តធម៌ ពឹងផ្អែក នូវនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ មានវារៈ ៣ ។ នីវរណវិប្បយុត្តធម៌ ពឹងផ្អែក នូវនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែក នូវខន្ធ ១ ជានីវរណវិប្បយុត្ត នូវខន្ធ ២ ... បដិសន្ធិ ពួកនីវរណវិប្បយុត្តកខន្ធ ពឹងផ្អែក នូវមហាភូត ១ នូវវត្ថុ ។ នីវរណសម្បយុត្តធម៌ ពឹងផ្អែក នូវនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

## នីវរណសម្បយុត្តទុកេ បច្ចយវារោ

វត្ថុំ បច្ចយា នីវរណសម្បយុត្តា ខន្ធា ។ នីវរណវិប្បយុត្តំ ធម្មំ បច្ចយា នីវរណសម្បយុត្តោ ច នីវរណវិប្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា វត្ថុំ បច្ចយា នីវរណសម្បយុត្តា ខន្ធា មហាភូតេ បច្ចយា ចិត្តសមុដ្ឋានំ រូបំ ។ នីវរណសម្បយុត្តញ្ច នីវរណវិប្បយុត្តញ្ច ធម្មំ បច្ចយា នីវរណសម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នីវរណសម្បយុត្តំ ឯកំ ខន្ធញ្ច វត្ថុញ្ច បច្ចយា តយោ ខន្ធា ទ្វេ ខន្ធេ . . . ។ នីវរណសម្បយុត្តញ្ច នីវរណវិប្បយុត្តញ្ច ធម្មំ បច្ចយា នីវរណវិប្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នីវរណសម្បយុត្តេ ខន្ធេ ច មហាភូតេ ច បច្ចយា ចិត្តសមុដ្ឋានំ រូបំ ។ នីវរណសម្បយុត្តញ្ច នីវរណវិប្បយុត្តញ្ច ធម្មំ បច្ចយា នីវរណសម្បយុត្តោ ច នីវរណវិប្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា នីវរណសម្បយុត្តំ ឯកំ ខន្ធញ្ច វត្ថុញ្ច បច្ចយា តយោ ខន្ធា ទ្វេ ខន្ធេ . . . នីវរណសម្បយុត្តេ ខន្ធេ ច មហាភូតេ ច បច្ចយា ចិត្តសមុដ្ឋានំ រូបំ ។ សង្ខិត្តំ ។

ពួកនីវរណសម្បយុត្តកខន្ធ ពឹងផ្អែក នឹងវត្ថុ ។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី ពឹងផ្អែក នឹងនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ពួកនីវរណសម្បយុត្តកខន្ធ ពឹងផ្អែក នឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែក នឹងពួកមហាភូត ។ នីវរណសម្បយុត្តធម៌ ពឹងផ្អែក នឹងនីវរណសម្បយុត្តធម៌ផង នឹងនីវរណវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ពឹងផ្អែក នឹងខន្ធ ១ ជានីវរណសម្បយុត្តផង នឹងវត្ថុផង នឹងខន្ធ ២ ... ។ នីវរណវិប្បយុត្តធម៌ ពឹងផ្អែក នឹងនីវរណសម្បយុត្តធម៌ផង នឹងនីវរណវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប ពឹងផ្អែក នឹងពួកនីវរណសម្បយុត្តកខន្ធផង នឹងពួកមហាភូតផង ។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី ពឹងផ្អែក នឹងនីវរណសម្បយុត្តធម៌ផង នឹងនីវរណវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ពឹងផ្អែក នឹងខន្ធ ១ ជានីវរណសម្បយុត្តផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែក នឹងពួកនីវរណសម្បយុត្តកខន្ធផង នឹងពួកមហាភូតផង ។ សេចក្តីបំព្រួញ ។

(២០១) ហេតុយា ទ្វេ អារម្មណេ ចត្តារិ អធិបតិយា ទ្វេ អនន្តរេ ចត្តារិ ។ បេ ។ វិបាកេ ឯកំ អវិគតេ ទ្វេ ។

(២០២) នីវរណសម្បយុត្តំ ធម្មំ បច្ចយា នីវរណសម្បយុត្តោ ធម្មោ ឧប្បជ្ជតិ នហេតុបច្ចយា វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ បច្ចយា អវិជ្ជានីវរណំ ។ នីវរណវិប្បយុត្តំ ធម្មំ បច្ចយា នីវរណវិប្បយុត្តោ ធម្មោ ឧប្បជ្ជតិ នហេតុបច្ចយា អហេតុកំ នីវរណវិប្បយុត្តំ ឯកំ ខន្ធំ បច្ចយា តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ យាវ អសញ្ញសត្តា ចក្ខាយតនំ បច្ចយា ចក្ខុវិញ្ញាណំ កាយាយតនំ បច្ចយា កាយវិញ្ញាណំ វត្ថុំ បច្ចយា អហេតុកា នីវរណវិប្បយុត្តា ខន្ធា ។ នីវរណវិប្បយុត្តំ ធម្មំ បច្ចយា នីវរណសម្បយុត្តោ ធម្មោ ឧប្បជ្ជតិ នហេតុបច្ចយា វត្ថុំ បច្ចយា វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។ នីវរណសម្បយុត្តញ្ច នីវរណវិប្បយុត្តញ្ច ធម្មំ បច្ចយា នីវរណសម្បយុត្តោ ធម្មោ ឧប្បជ្ជតិ

[ ២០១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ។ បេ ។ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២០២ ] នីវរណសម្បយុត្តធម៌ ពឹងផ្អែក នឹងនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ អវិជ្ជានីវរណៈ ពឹងផ្អែក នឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ នីវរណវិប្បយុត្តធម៌ ពឹងផ្អែក នឹងនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែក នឹងខន្ធ ១ ជាអហេតុកៈ ជានីវរណវិប្បយុត្ត ដរាបដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ ពឹងផ្អែក នឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែក នឹងកាយាយតនៈ ពួកនីវរណវិប្បយុត្តកខន្ធ ជាអហេតុកៈ ពឹងផ្អែក នឹងវត្ថុ ។ នីវរណសម្បយុត្តធម៌ ពឹងផ្អែក នឹងនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែក នឹងវត្ថុ ។ នីវរណសម្បយុត្តធម៌ ពឹងផ្អែក នឹងនីវរណសម្បយុត្តធម៌ផង នឹងនីវរណវិប្បយុត្តធម៌ផង ទើបកើតឡើង

នហេតុប្បច្ចយា វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ ច វត្ថុញ្ច បច្ចយា វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។ សង្ខិត្តំ ។

(២០៣) នហេតុយា ចត្តារិ នអារម្មណេ តីណិ ។បេ។ នបុរេជាតេ ចត្តារិ នបច្ឆាជាតេ នវ នអាសេវនេ នវ នកម្មេ ចត្តារិ នវិបាកេ នវ នសម្បយុត្តេ តីណិ នវិប្បយុត្តេ ទ្វេ នោនត្ថិយា តីណិ នោវិគតេ តីណិ ។

ឯវំ ឥតរេ ទ្វេ គណនាបិ
និស្សយវារោបិ កាតព្វា ។

## សំសដ្ឋវារោ

(២០៤) នីវរណសម្បយុត្តំ ធម្មំ សំសដ្ឋោ នីវរណសម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(២០៥) ហេតុយា ទ្វេ អារម្មណេ ទ្វេ សព្វត្ថ ទ្វេ វិបាកេ ឯកំ អវិគតេ ទ្វេ ។

ព្រោះនហេតុប្បច្ច័យ គឺ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែក នឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។ សេចក្តីបំប្រួញ ។

[ ២០៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ។ បេ ។ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់វារៈ ទាំង ២ ក្រៅពីនេះក្តី និស្សយវារៈក្តី បណ្ឌិត គប្បីធ្វើ យ៉ាងនេះចុះ ។

## សំសដ្ឋវារៈ

[ ២០៤ ] នីវរណសម្បយុត្តធម៌ លាយឡំ នឹងនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ២០៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ២ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[២០៦] និវរណសម្បយុត្តំ ធម្មំ សំសដ្ឋោ និវរណសម្បយុត្តោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ សំសដ្ឋោ វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។ និវរណវិប្បយុត្តំ ធម្មំ សំសដ្ឋោ ... ។

[២០៧] នហេតុយា ទ្វេ នអធិបតិយា ទ្វេ នបុរេជាតេ ទ្វេ នកម្មេ ទ្វេ នវិបាកេ ទ្វេ នឈានេ ឯកំ នមគ្គេ ឯកំ នវិប្បយុត្តេ ទ្វេ ។

ឯវំ ឥតរេ ទ្វេ គណនាបិ
សម្បយុត្តវារេបិ កាតព្វា ។

## បញ្ហាវារោ

[២០៨] និវរណសម្បយុត្តោ ធម្មោ និវរណសម្បយុត្តស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ និវរណសម្បយុត្តា ហេតូ សម្បយុត្តកានំ ខន្ធានំ ហេតុប្បច្ចយេន បច្ចយោ ។ មូលានិ បុច្ឆិតព្វានិ ។ និវរណសម្បយុត្តា ហេតូ ចិត្តសមុដ្ឋានានំ រូបានំ ហេតុប្បច្ចយេន បច្ចយោ ។ និវរណសម្បយុត្តា ហេតូ

(២០៦) នីវរណសម្បយុត្តធម៌ លាយឡំ នឹងនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ លាយឡំ នឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ លាយឡំ នឹងនីវរណវិប្បយុត្តធម៌ ... ។

(២០៧) ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។

ការរាប់វារៈ ទាំង ២ ក្រៅពីនេះក្តី សម្បយុត្តវារៈក្តី
បណ្ឌិត គប្បីធ្វើ យ៉ាងនេះចុះ ។

# បញ្ហាវារៈ

(២០៨) នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺ ពួកនីវរណសម្បយុត្តហេតុ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ មូលទាំងឡាយ បណ្ឌិត គប្បីសួរផងចុះ ។ ពួកនីវរណសម្បយុត្តហេតុ ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។ ពួកនីវរណសម្បយុត្តហេតុ

សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ ។ នីវរណវិប្បយុត្តោ ធម្មោ នីវរណវិប្បយុត្តស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ នីវរណវិប្បយុត្តា ហេតូ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ បដិសន្ធិ ។

(២០៩) នីវរណសម្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ រាគំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចំ ទោមនស្សំ ឧប្បជ្ជតិ ទិដ្ឋឹ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចំ ទោមនស្សំ ឧប្បជ្ជតិ វិចិកិច្ឆំ អារព្ភ វិចិកិច្ឆា ទិដ្ឋិ ឧទ្ធច្ចំ ទោមនស្សំ ឧទ្ធច្ចំ អារព្ភ ឧទ្ធច្ចំ ឧប្បជ្ជតិ ទិដ្ឋិ ... វិចិកិច្ឆា ឧប្បជ្ជតិ ទោមនស្សំ អារព្ភ ទោមនស្សំ ឧប្បជ្ជតិ ទិដ្ឋិ ... វិចិកិច្ឆា ... ឧទ្ធច្ចំ ឧប្បជ្ជតិ ។ នីវរណសម្បយុត្តោ ធម្មោ នីវរណវិប្បយុត្តស្ស ធម្មស្ស

ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺ ពួកនីវរណវិប្បយុត្តហេតុ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ គឺ ជាបដិសន្ធិ ។

( ២០៩ ) នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺ បុគ្គល ត្រេកអរ រីករាយ ចំពោះរាគៈ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ ទោមនស្ស កើតឡើង ព្រោះប្រារព្ធ នូវហេតុនោះ ត្រេកអរ រីករាយ ចំពោះទិដ្ឋិ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ ទោមនស្ស កើតឡើង ព្រោះប្រារព្ធ នូវហេតុនោះ វិចិកិច្ឆា ទិដ្ឋិ ឧទ្ធច្ចៈ ទោមនស្ស កើតឡើង ព្រោះប្រារព្ធ នូវវិចិកិច្ឆា ឧទ្ធច្ចៈ កើតឡើង ព្រោះប្រារព្ធ នូវឧទ្ធច្ចៈ ទិដ្ឋិ ... វិចិកិច្ឆា កើតឡើង ទោមនស្ស កើតឡើង ព្រោះប្រារព្ធ នូវទោមនស្ស ទិដ្ឋិ ... វិចិកិច្ឆា ... ឧទ្ធច្ចៈ កើតឡើង ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌

អារម្មណប្បច្ចយេន បច្ចយោ អរិយា នីវរណសម្បយុត្តេ បហីនេ កិលេសេ(១) បច្ចវេក្ខន្តិ វិក្ខម្ភិតេ កិលេសេ បច្ចវេក្ខន្តិ បុព្វេ សមុទាចិណ្ណេ កិលេសេ ជានន្តិ នីវរណសម្បយុត្តេ ខន្ធេ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ ចេតោបរិយញ្ញាណេន នីវរណសម្បយុត្តចិត្តសមង្គិស្ស ចិត្តំ ជានាតិ នីវរណសម្បយុត្តា ខន្ធា ឥទ្ធិវិធញ្ញាណស្ស ចេតោបរិយញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មូបគញ្ញាណស្ស អនាគតំសញ្ញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។ នីវរណវិប្បយុត្តោ ធម្មោ នីវរណវិប្បយុត្តស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ទានំ ... សីលំ ... ឧបោសថកម្មំ ... តំ បច្ចវេក្ខតិ បុព្វេ សុចិណ្ណានិ ... ឈានា វុដ្ឋហិត្វា ឈានំ ... អរិយា មគ្គា វុដ្ឋហិត្វា មគ្គំ ... ផលំ បច្ចវេក្ខន្តិ និព្វានំ ... និព្វានំ គោត្រភុស្ស វោទានស្ស មគ្គស្ស ផលស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ចក្ខុំ ... វត្ថុំ នីវរណវិប្បយុត្តេ ខន្ធេ អនិច្ចតោ ទុក្ខតោ

១ ម. នីវរណសម្បយុត្តំ បហីនក្កិលេសំ ។

ដោយអារម្មណប្បច្ច័យ គឺ ពួកព្រះអរិយៈ ពិចារណា នូវពួកកិលេស ជានីវរណសម្បយុត្ត ដែលខ្លួនលះបង់ហើយ ពិចារណា នូវពួកកិលេស ដែលខ្លួនសង្កត់សង្កិនហើយ ដឹង នូវពួកកិលេស ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ឃើញ នូវពួកនីវរណសម្បយុត្តក្ខន្ធ ជាមិនទៀង ជាទុក្ខ ជាអនត្តា ដឹង នូវចិត្ត នៃបុគ្គលអ្នកប្រកបដោយនីវរណសម្បយុត្តចិត្ត ដោយចេតោបរិយញ្ញាណ ពួកនីវរណសម្បយុត្តក្ខន្ធ ជាបច្ច័យ នៃការពិចារណា នូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺ នូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ពិចារណា នូវហេតុនោះ (នូវពួកអំពើ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ... ចេញ អំពីឈាន នូវឈាន ... ពួកព្រះអរិយៈ ចេញ អំពីមគ្គ នូវមគ្គ ... ពិចារណា នូវផល នូវព្រះនិព្វាន ... ព្រះនិព្វាន ជាបច្ច័យ នៃកិរិយាពិចារណា នូវគោត្រភូ វោទានៈ មគ្គ និងផល ដោយអារម្មណប្បច្ច័យ នូវចក្ខុ ... ឃើញច្បាស់ នូវវត្ថុ នូវពួកនីវរណវិប្បយុត្តក្ខន្ធ ជាមិនទៀង ជាទុក្ខ

អនត្តតោ វិបស្សតិ ទិព្វេន ចក្ខុនា រូបំ បស្សតិ យាវ អាវជ្ជនាយ ។ នីវរណវិប្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ទានំ ... សីលំ ... ឧបោសថកម្មំ ... បុព្វេ ... ឈានា ... ចក្ខុំ ... វត្ថុំ ... នីវរណវិប្បយុត្តេ ខន្ធេ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចំ ទោមនស្សំ ឧប្បជ្ជតិ ។

( ២១០ ) នីវរណសម្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ សហជាតាធិបតិ ។ អារម្មណាធិបតិ រាគំ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ទិដ្ឋិ ឧប្បជ្ជតិ ។ សហជាតាធិបតិ នីវរណសម្បយុត្តាធិបតិ នីវរណសម្បយុត្តានំ ខន្ធានំ អធិបតិប្បច្ចយេន បច្ចយោ ។ នីវរណសម្បយុត្តោ ធម្មោ នីវរណវិប្បយុត្តស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ សហជាតាធិបតិ នីវរណសម្បយុត្តាធិបតិ ចិត្តសមុដ្ឋានានំ រូបានំ អធិបតិប្បច្ចយេន បច្ចយោ ។ មូលំ បុច្ឆិតព្វំ នីវរណសម្បយុត្តាធិបតិ សម្បយុត្តកានំ ខន្ធានំ

ជាអនត្តា ឃើញ នូវរូប ដោយទិព្វចក្ខុ ដរាបអំពីអាវជ្ជនៈ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយអារម្មណបច្ច័យ គឺ នូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ក្នុងកាលមុន ... អំពីឈាន ... នូវចក្ខុ ... នូវវត្ថុ ... បុគ្គល ត្រេកអរ រីករាយ ចំពោះពួកនីវរណវិប្បយុត្តក្ខន្ធ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ ទោមនស្ស កើតឡើង ព្រោះប្រារព្ធ នូវហេតុនោះ ។

( ៦១០ ) នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយអធិបតិបច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ បុគ្គល ត្រេកអរ រីករាយ ព្រោះធ្វើ នូវរាគៈ ឲ្យជាទីគោរព រាគៈ ទិដ្ឋិ កើតឡើង ព្រោះធ្វើ នូវរាគៈនោះឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺ នីវរណសម្បយុត្តាធិបតិ ជាបច្ច័យ នៃពួកនីវរណសម្បយុត្តក្ខន្ធ ដោយអធិបតិបច្ច័យ ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយអធិបតិបច្ច័យ បានដល់សហជាតាធិបតិ គឺ នីវរណសម្បយុត្តាធិបតិ ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិបច្ច័យ ។ មូល បណ្ឌិត គប្បីសួរ ផងចុះ នីវរណសម្បយុត្តាធិបតិ ជាបច្ច័យ នៃពួកសម្បយុត្តក្ខន្ធផង

ចិត្តសមុដ្ឋានានញ្ច រូបានំ អធិបតិប្បច្ចយេន បច្ចយោ ។ នីវរណវិប្បយុត្តោ ធម្មោ នីវរណវិប្បយុត្តស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ សហជាតាធិបតិ ។ អារម្មណាធិបតិ ទានំ ... សីលំ ... ឧបោសថកម្មំ ... តំ គរុំ កត្វា បច្ចវេក្ខតិ បុព្វេ សុចិណ្ណានិ ... ឈានា វុដ្ឋហិត្វា ឈានំ ... អរិយា មគ្គា វុដ្ឋហិត្វា មគ្គំ គរុំ កត្វា ... ផលំ ... និព្វានំ ... និព្វានំ គោត្រភុស្ស វោទានស្ស មគ្គស្ស ផលស្ស អធិបតិប្បច្ចយេន បច្ចយោ ។ សហជាតាធិបតិ នីវរណវិប្បយុត្តាធិបតិ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ អធិបតិប្បច្ចយេន បច្ចយោ ។ នីវរណវិប្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ ទានំ ... ។ បេ ។ បុព្វេ ... ឈានំ ... ចក្ខុំ ... វត្ថុំ ... នីវរណវិប្បយុត្តេ ខន្ធេ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ទិដ្ឋិ ឧប្បជ្ជតិ ។

នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ បុគ្គល នូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ធ្វើ នូវហេតុនោះ ឲ្យជាទីគោរព ហើយពិចារណា (នូវពួកអំពើ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ... ចេញ អំពីឈាន នូវឈាន ... ពួកព្រះអរិយៈចេញ អំពីមគ្គ ធ្វើ នូវមគ្គ ឲ្យជាទីគោរព ... នូវផល ... នូវព្រះនិព្វាន ... ព្រះនិព្វាន ជាបច្ច័យ នៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្បច្ច័យ ។ ឯសហជាតាធិបតិ គឺ នីវរណវិប្បយុត្តាធិបតិ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺ នូវទាន ... ។ បេ ។ ក្នុងកាលមុន ... នូវឈាន ... នូវចក្ខុ ... នូវវត្ថុ ... ធ្វើ នូវពួកនីវរណវិប្បយុត្តក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ ទិដ្ឋិ កើតឡើង ព្រោះធ្វើ នូវហេតុនោះ ឲ្យជាទីគោរព ។

( ២១១ ) នីវរណសម្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ បុរិមា បុរិមា នីវរណសម្បយុត្តា ខន្ធា បច្ឆិមានំ បច្ឆិមានំ នីវរណសម្បយុត្តានំ ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ ។ មូលំ បុច្ឆិតព្វំ(១) នីវរណសម្បយុត្តា ខន្ធា វុដ្ឋានស្ស អនន្តរប្បច្ចយេន បច្ចយោ ឥធ បុរិមា បុរិមា នត្ថិ ។ មូលំ បុច្ឆិតព្វំ បុរិមា បុរិមា នីវរណវិប្បយុត្តា ខន្ធា បច្ឆិមានំ បច្ឆិមានំ នីវរណវិប្បយុត្តានំ ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ អនុលោមំ ផលសមាបត្តិយា អនន្តរប្បច្ចយេន បច្ចយោ ។ នីវរណវិប្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ អាវជ្ជនា នីវរណសម្បយុត្តានំ ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ ។ នីវរណសម្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស សមនន្តរប្បច្ចយេន បច្ចយោ ។ សហជាតប្បច្ចយេន បច្ចយោ អញ្ញមញ្ញប្បច្ចយេន បច្ចយោ និស្សយប្បច្ចយេន បច្ចយោ ។

---

១ ម. មូលា បុច្ឆិតព្វា ។

នីវរណសម្បយុត្តទុកៈ បញ្ហាវារៈ

[ ២១១ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺ ពួកនីវរណសម្បយុត្តក្ខន្ធ មុន ៗ ជាបច្ច័យ នៃពួកនីវរណសម្បយុត្តក្ខន្ធ ក្រោយ ៗ ដោយអនន្តរប្បច្ច័យ ។ មូល បណ្ឌិត គប្បីសួរផងចុះ ពួកនីវរណសម្បយុត្តក្ខន្ធ ជាបច្ច័យ នៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ (ខន្ធ ៣) មុន ៗ មិនមាន ក្នុងទីនេះទេ ។ មូល បណ្ឌិត គប្បីសួរផងចុះ ពួកនីវរណវិប្បយុត្តក្ខន្ធ មុន ៗ ជាបច្ច័យ នៃពួកនីវរណវិប្បយុត្តក្ខន្ធ ក្រោយ ៗ ដោយអនន្តរប្បច្ច័យ គឺ អនុលោមញាណ ជាបច្ច័យ នៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺ អាវជ្ជនៈ ជាបច្ច័យ នៃពួកនីវរណសម្បយុត្តក្ខន្ធ ដោយអនន្តរប្បច្ច័យ ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយសមនន្តរប្បច្ច័យ ។ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យ ដោយនិស្សយប្បច្ច័យ ។

(២១២) នីវរណសម្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ អារម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។បេ។ បកតូបនិស្សយោ រាគំ ឧបនិស្សាយ បាណំ ហនតិ ។បេ។ សង្ឃំ ភិន្ទតិ ទោសំ ... មោហំ មានំ ទិដ្ឋិំ ... បត្ថនំ ឧបនិស្សាយ បាណំ ហនតិ ។បេ។ សង្ឃំ ភិន្ទតិ រាគោ ។បេ។ បត្ថនា រាគស្ស ។បេ។ បត្ថនាយ ឧបនិស្សយប្បច្ចយេន បច្ចយោ ។ នីវរណសម្បយុត្តោ ធម្មោ នីវរណវិប្បយុត្តស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។បេ។ បកតូបនិស្សយោ រាគំ ឧបនិស្សាយ ទានំ ទេតិ សីលំ ... ឧបោសថកម្មំ ឈានំ វិបស្សនំ មគ្គំ អភិញ្ញំ ... សមាបត្តឹ ឧប្បាទេតិ ទោសំ ... បត្ថនំ ឧបនិស្សាយ ទានំ ទេតិ ។បេ។ សមាបត្តឹ ឧប្បាទេតិ រាគោ ។បេ។ បត្ថនា សទ្ធាយ ។បេ។ បញ្ញាយ កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស មគ្គស្ស ផលសមាបត្តិយា ឧបនិស្សយប្បច្ចយេន បច្ចយោ ។

( ២១២ ) នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បេ ។ ឯបកតូបនិស្ស័យ គឺ បុគ្គល អាស្រ័យ នូវរាគៈ ហើយសម្លាប់ នូវសត្វ ។ បេ ។ បំបែក នូវសង្ឃ នូវទោសៈ . . . នូវមោហៈ មានៈ និងទិដ្ឋិ . . . អាស្រ័យ នូវសេចក្ដីប្រាថ្នា ហើយសម្លាប់ នូវសត្វ ។ បេ ។ បំបែក នូវ សង្ឃ រាគៈ ។ បេ ។ សេចក្ដីប្រាថ្នា (ជាបច្ច័យ) នៃរាគៈ ។ បេ ។ ជាបច្ច័យ នៃសេចក្ដីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បេ ។ ឯបកតូបនិស្ស័យ គឺ បុគ្គល អាស្រ័យ នូវរាគៈ ហើយឲ្យ នូវទាន នូវសីល . . . នូវឧបោសថកម្ម ញុំាងឈាន វិបស្សនា មគ្គ និងអភិញ្ញា . . . ញុំាងសមាបត្តិ ឲ្យកើតឡើង នូវទោសៈ ... អាស្រ័យ នូវសេចក្ដីប្រាថ្នា ហើយឲ្យ នូវទាន ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង រាគៈ ។ បេ ។ សេចក្ដីប្រាថ្នា (ជាបច្ច័យ) នៃសទ្ធា ។ បេ ។ ជាបច្ច័យ នៃបញ្ញា កាយិកសុខ កាយិកទុក្ខ មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

នីវរណវិប្បយុត្តោ ធម្មោ នីវរណវិប្បយុត្តស្ស ធម្មស្ស ឧបនិស្សយបច្ចយេន បច្ចយោ អារម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បេ ។ បកតូបនិស្សយោ សទ្ធំ ឧបនិស្សាយ ទានំ ទេតិ សីលំ ... ។ បេ ។ មគ្គំ ... អភិញ្ញំ ... សមាបត្តឹ ឧប្បាទេតិ សីលំ ... ។ បេ ។ បញ្ញំ ... ។ បេ ។ សេនាសនំ ឧបនិស្សាយ ទានំ ទេតិ ។ បេ ។ សមាបត្តឹ ឧប្បាទេតិ សទ្ធា ។ បេ ។ សេនាសនំ សទ្ធាយ ។ បេ ។ បញ្ញាយ មគ្គស្ស ផលសមាបត្តិយា ឧបនិស្សយប្បច្ចយេន បច្ចយោ ។ នីវរណវិប្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ អារម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បេ ។ បកតូបនិស្សយោ សទ្ធំ ឧបនិស្សាយ មានំ ជប្បេតិ ទិដ្ឋឹ គណ្ហាតិ សីលំ ... ។ បេ ។ បញ្ញំ ... កាយិកំ ... ។ បេ ។ សេនាសនំ ឧបនិស្សាយ បាណំ ហនតិ ។ បេ ។ សង្ឃំ ភិន្ទតិ សទ្ធា ។ បេ ។ សេនាសនំ រាគស្ស ទោសស្ស មោហស្ស មានស្ស ទិដ្ឋិយា បត្ថនាយ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយឧបនិស្ស-យប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូ-បនិស្ស័យ ។ បេ ។ ឯបកតូបនិស្ស័យ គឺ បុគ្គល អាស្រ័យ នូវសទ្ធា ហើយឲ្យ នូវទាន នូវសីល ... ។ បេ ។ ញុំាងមគ្គ ... ញុំាងអភិញ្ញា ... ញុំាងសមាបត្តិ ឲ្យកើតឡើង នូវសីល ... ។ បេ ។ នូវបញ្ញា ... ។ បេ ។ បុគ្គល អាស្រ័យ នូវសេនាសនៈ ហើយឲ្យ នូវទាន ។ បេ ។ ញុំាងសមាបត្តិ ឲ្យកើតឡើង សទ្ធា ។ បេ ។ សេនាសនៈ (ជាបច្ច័យ) នៃសទ្ធា ។ បេ ។ ជាបច្ច័យ នៃបញ្ញា មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្ប-យុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្ត-រូបនិស្ស័យ និងបកតូបនិស្ស័យ ។ បេ ។ ឯបកតូនិស្ស័យ គឺ បុគ្គល អា-ស្រ័យ នូវសទ្ធា ហើយដំឡើង នូវមានៈ ប្រកាន់ នូវទិដ្ឋិ នូវសីល ... ។ បេ ។ នូវបញ្ញា ... កាយិកៈ ... ។ បេ ។ អាស្រ័យ នូវសេនា-សនៈ ហើយសម្លាប់ នូវសត្វ ។ បេ ។ បំបែក នូវសង្ឃ សទ្ធា ។ បេ ។ សេនាសនៈ ជាបច្ច័យ នៃរាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

[២១៣] និវរណវិប្បយុត្តោ ធម្មោ និវរណវិប្បយុត្តស្ស ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ អារម្មណបុរេជាតំ វត្ថុបុរេជាតំ ។ អារម្មណបុរេជាតំ ចក្ខុំ ... វត្ថុំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ ទិព្វេន ចក្ខុនា រូបំ បស្សតិ ទិព្វាយ សោតធាតុយា សទ្ទំ សុណាតិ រូបាយតនំ ចក្ខុវិញ្ញាណស្ស ផោដ្ឋព្វាយតនំ កាយវិញ្ញាណស្ស ។ វត្ថុបុរេជាតំ ចក្ខាយតនំ ចក្ខុវិញ្ញាណស្ស កាយាយតនំ កាយវិញ្ញាណស្ស វត្ថុ និវរណវិប្បយុត្តានំ ខន្ធានំ បុរេជាតប្បច្ចយេន បច្ចយោ ។ និវរណវិប្បយុត្តោ ធម្មោ និវរណសម្បយុត្តស្ស ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ អារម្មណបុរេជាតំ វត្ថុបុរេជាតំ ។ អារម្មណបុរេជាតំ ចក្ខុំ ... វត្ថុំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ទោសោ មោហោ ។ វត្ថុបុរេជាតំ វត្ថុ និវរណសម្បយុត្តានំ ខន្ធានំ បុរេជាតប្បច្ចយេន បច្ចយោ ។

[២១៤] និវរណសម្បយុត្តោ ធម្មោ និវរណវិប្បយុត្តស្ស ធម្មស្ស បច្ឆាជាតប្បច្ចយេន បច្ចយោ ទ្វេ ។

អាសេវនប្បច្ចយេន បច្ចយោ ទ្វេ ។

(២១៣) នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ នូវចក្ខុ ... ឃើញច្បាស់ នូវវត្ថុ ថាមិនទៀង ជាទុក្ខ ជាអនត្តា ឃើញ នូវរូប ដោយទិព្វចក្ខុ ឮ នូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺ ចក្ខាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ កាយាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យ នៃពួកនីវរណវិប្បយុត្តក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ នូវចក្ខុ ... ត្រេកអរ រីករាយ ចំពោះវត្ថុ រាគៈ ទោសៈ មោហៈ (កើតឡើង) ព្រោះប្រារព្ធ នូវហេតុនោះ ។ ឯវត្ថុបុរេជាត គឺ វត្ថុ ជាបច្ច័យ នៃពួកនីវរណសម្បយុត្តក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។

(២១៤) នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺ មានវារៈ ២ ។ ជាបច្ច័យ ដោយអាសេវនប្បច្ច័យ គឺ មានវារៈ ២ ។

[ ២១៥ ] នីវរណសម្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ នីវរណសម្បយុត្តា ចេតនា សម្បយុត្តកានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។ មូលានិ កាតព្វានិ ។ សហជាតា នានាខណិកា ។ សហជាតា នីវរណសម្បយុត្តា ចេតនា ចិត្តសមុដ្ឋានានំ រូបានំ កម្មប្បច្ចយេន បច្ចយោ ។ នានាខណិកា នីវរណសម្បយុត្តា ចេតនា វិបាកានំ ខន្ធានំ កដត្តា ច រូបានំ កម្មប្បច្ចយេន បច្ចយោ ។ នីវរណសម្បយុត្តា ចេតនា សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ កម្មប្បច្ចយេន បច្ចយោ ។ នីវរណវិប្បយុត្តោ ធម្មោ នីវរណវិប្បយុត្តស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ សហជាតា នានាខណិកា ។ សង្ខិត្តំ ។ វិបាកប្បច្ចយេន បច្ចយោ ឯកំ ។

[ ២១៦ ] នីវរណសម្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស អាហារប្បច្ចយេន បច្ចយោ ។ ឥន្ទ្រិយប្បច្ចយេន បច្ចយោ ឈានប្បច្ចយេន បច្ចយោ មគ្គប្បច្ចយេន បច្ចយោ សម្បយុត្តប្បច្ចយេន បច្ចយោ ទ្វេ ។

[ ២១៥ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយកម្មប្បច្ច័យ គឺ នីវរណសម្បយុត្តចេតនា ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ មូលទាំងឡាយ បណ្ឌិតគប្បីធ្វើផងចុះ ។ បានដល់សហជាត និងនានាខណិកៈ ។ សហជាត គឺ នីវរណសម្បយុត្តចេតនា ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺ នីវរណសម្បយុត្តចេតនា ជាបច្ច័យ នៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ នីវរណសម្បយុត្តចេតនា ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ ។ សេចក្តីបំប្រួញ ។ ជាបច្ច័យ ដោយវិបាកប្បច្ច័យ គឺ មានវារៈ ១ ។

[ ២១៦ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយអាហារប្បច្ច័យ ។ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យ ដោយឈានប្បច្ច័យ ជាបច្ច័យ ដោយមគ្គប្បច្ច័យ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ គឺ មានវារៈ ២ ។

[២១៧] នីវរណសម្បយុត្តោ ធម្មោ នីវរណវិប្បយុត្តស្ស ធម្មស្ស វិប្បយុត្តប្បច្ចយេន បច្ចយោ សហជាតំ បច្ឆាជាតំ ។ សង្ខិត្តំ ។ នីវរណវិប្បយុត្តោ ធម្មោ នីវរណវិប្បយុត្តស្ស ធម្មស្ស វិប្បយុត្តប្បច្ចយេន បច្ចយោ សហជាតំ បុរេជាតំ បច្ឆាជាតំ ។ សង្ខិត្តំ ។ នីវរណវិប្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស វិប្បយុត្តប្បច្ចយេន បច្ចយោ បុរេជាតំ វត្ថុ នីវរណសម្បយុត្តានំ ខន្ធានំ វិប្បយុត្តប្បច្ចយេន បច្ចយោ ។

[២១៨] នីវរណសម្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស អត្ថិប្បច្ចយេន បច្ចយោ នីវរណសម្បយុត្តោ ឯកោ ខន្ធោ តិណ្ណន្នំ ខន្ធានំ អត្ថិប្បច្ចយេន បច្ចយោ ។ នីវរណសម្បយុត្តោ ធម្មោ នីវរណវិប្បយុត្តស្ស ធម្មស្ស អត្ថិប្បច្ចយេន បច្ចយោ សហជាតំ បុរេជាតំ បច្ឆាជាតំ ។ សហជាតា នីវរណសម្បយុត្តា ខន្ធា ចិត្តសមុដ្ឋានានំ រូបានំ អត្ថិប្បច្ចយេន បច្ចយោ ។ បច្ឆាជាតា នីវរណសម្បយុត្តា ខន្ធា បុរេជាតស្ស ឥមស្ស កាយស្ស អត្ថិប្បច្ចយេន បច្ចយោ ។ នីវរណសម្បយុត្តោ ធម្មោ

[ ២១៧ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត ។ សេចក្ដីបំប្រួញ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត បុរេជាត និងបច្ឆាជាត ។ សេចក្ដីបំប្រួញ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់បុរេជាត គឺ វត្ថុ ជាបច្ច័យ នៃពួកនីវរណសម្បយុត្តក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។

[ ២១៨ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ គឺ ខន្ធ ១ ជានីវរណសម្បយុត្ត ជាបច្ច័យ នៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺ ពួកនីវរណសម្បយុត្តក្ខន្ធ ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺ ពួកនីវរណសម្បយុត្តក្ខន្ធ ជាបច្ច័យ នៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ នីវរណសម្បយុត្តធម៌

នីវរណសម្បយុត្តស្ស ច នីវរណវិប្បយុត្តស្ស ច ធម្មស្ស អត្ថិប្បច្ចយេន បច្ចយោ នីវរណសម្បយុត្តោ ឯកោ ខន្ធោ តិណ្ណន្នំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ អត្ថិប្បច្ចយេន បច្ចយោ ទ្វេ ខន្ធា ទ្វិន្នំ ខន្ធានំ អត្ថិប្បច្ចយេន បច្ចយោ ។ នីវរណវិប្បយុត្តោ ធម្មោ នីវរណវិប្បយុត្តស្ស ធម្មស្ស អត្ថិប្បច្ចយេន បច្ចយោ សហជាតំ បុរេជាតំ បច្ឆាជាតំ អាហារំ ឥន្ទ្រិយំ ។ សង្ខិត្តំ ។ នីវរណវិប្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស អត្ថិប្បច្ចយេន បច្ចយោ បុរេជាតំ ចក្ខុំ ... វត្ថុំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចំ ទោមនស្សំ ឧប្បជ្ជតិ វត្ថុ នីវរណសម្បយុត្តានំ ខន្ធានំ អត្ថិប្បច្ចយេន បច្ចយោ ។ នីវរណសម្បយុត្តោ ច នីវរណវិប្បយុត្តោ ច ធម្មា នីវរណសម្បយុត្តស្ស ធម្មស្ស អត្ថិប្បច្ចយេន បច្ចយោ សហជាតំ បុរេជាតំ ។ សហជាតោ នីវរណសម្បយុត្តោ ឯកោ ខន្ធោ ច វត្ថុ ច តិណ្ណន្នំ ខន្ធានំ អត្ថិប្បច្ចយេន បច្ចយោ ទ្វេ ខន្ធា ច វត្ថុ ច ទ្វិន្នំ ខន្ធានំ អត្ថិប្បច្ចយេន បច្ចយោ ។ នីវរណសម្បយុត្តោ ច នីវរណវិប្បយុត្តោ ច ធម្មា

ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ផង នៃនីវរណវិប្បយុត្តធម៌ផង ដោយអត្ថិប្បច្ច័យ គឺ ខន្ធ ១ ជានីវរណសម្បយុត្ត ជាបច្ច័យ នៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យ នៃខន្ធ ២ ដោយអត្ថិប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សេចក្តីបំប្រួញ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់បុរេជាត គឺ បុគ្គល នូវចក្ខុ ... ត្រេកអរ រីករាយ ចំពោះវត្ថុ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធ នូវហេតុនោះ វត្ថុ ជាបច្ច័យ នៃពួកនីវរណសម្បយុត្តខន្ធ ដោយអត្ថិប្បច្ច័យ ។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត ។ សហជាត គឺ ខន្ធ ១ ជានីវរណសម្បយុត្តផង វត្ថុផង ជាបច្ច័យ នៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ផង វត្ថុផង ជាបច្ច័យ នៃខន្ធ ២ ដោយអត្ថិប្បច្ច័យ ។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី

នីវរណវិប្បយុត្តស្ស ធម្មស្ស អត្ថិប្បច្ចយេន បច្ចយោ សហជាតំ បច្ឆាជាតំ អាហារំ ឥន្ទ្រិយំ ។ សហជាតា នីវរណសម្បយុត្តា ខន្ធា ច មហាភូតា ច ចិត្តសមុដ្ឋានានំ រូបានំ អត្ថិប្បច្ចយេន បច្ចយោ ។ បច្ឆាជាតា នីវរណសម្បយុត្តា ខន្ធា ច កពឡីការោ អាហារោ ច ឥមស្ស កាយស្ស អត្ថិប្បច្ចយេន បច្ចយោ បច្ឆាជាតា នីវរណសម្បយុត្តា ខន្ធា ច រូបជីវិតិន្ទ្រិយញ្ច កដត្តារូបានំ អត្ថិប្បច្ចយេន បច្ចយោ ។

(២១៩) ហេតុយា ចត្តារិ អារម្មណេ ចត្តារិ អធិបតិយា បញ្ច អនន្តរេ ចត្តារិ សមនន្តរេ ចត្តារិ សហជាតេ បញ្ច អញ្ញមញ្ញេ ទ្វេ និស្សយេ សត្ត ឧបនិស្សយេ ចត្តារិ បុរេជាតេ ទ្វេ បច្ឆាជាតេ ទ្វេ អាសេវនេ ទ្វេ កម្មេ ចត្តារិ វិបាកេ ឯកំ អាហារេ ចត្តារិ ឥន្ទ្រិយេ ចត្តារិ ឈានេ ចត្តារិ មគ្គេ ចត្តារិ សម្បយុត្តេ ទ្វេ វិប្បយុត្តេ តីណិ អត្ថិយា សត្ត នត្ថិយា ចត្តារិ វិគតេ ចត្តារិ អវិគតេ សត្ត ។

ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺ ពួកនីវរណវិប្បយុត្តក្ខន្ធផង ពួកមហាភូតផង ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺ ពួកនីវរណសម្បយុត្តក្ខន្ធផង កពឡិង្ការាហារផង ជាបច្ច័យ នៃកាយនេះ ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺ ពួកនីវរណសម្បយុត្តក្ខន្ធផង រូបជីវិតិន្ទ្រិយផង ជាបច្ច័យ នៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[២១៩] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងវិគតប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

(២២០) នីវរណសម្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ ។ នីវរណសម្បយុត្តោ ធម្មោ នីវរណវិប្បយុត្តស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ បច្ឆាជាតប្បច្ចយេន បច្ចយោ កម្មប្បច្ចយេន បច្ចយោ ។ នីវរណសម្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ច នីវរណវិប្បយុត្តស្ស ច ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ ។ នីវរណវិប្បយុត្តោ ធម្មោ នីវរណវិប្បយុត្តស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ បុរេជាតប្បច្ចយេន បច្ចយោ បច្ឆាជាតប្បច្ចយេន បច្ចយោ អាហារប្បច្ចយេន បច្ចយោ ឥន្ទ្រិយប្បច្ចយេន បច្ចយោ ។ នីវរណវិប្បយុត្តោ ធម្មោ នីវរណសម្បយុត្តស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ បុរេជាតប្បច្ចយេន បច្ចយោ ។ នីវរណសម្បយុត្តោ ច

[ ៦៦០ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ផង នៃនីវរណវិប្បយុត្តធម៌ផង ដោយសហជាតប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ។ នីវរណសម្បយុត្តធម៌គឺ

នីវរណវិប្បយុត្តោ ច ធម្មា នីវរណសម្បយុត្តស្ស ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ បុរេជាតប្បច្ចយេន បច្ចយោ ។ នីវរណសម្បយុត្តោ ច នីវរណវិប្បយុត្តោ ច ធម្មា នីវរណវិប្បយុត្តស្ស ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ បច្ឆាជាតប្បច្ចយេន បច្ចយោ អាហារប្បច្ចយេន បច្ចយោ ឥន្ទ្រិយប្បច្ចយេន បច្ចយោ ។

(២២១) នហេតុយា សត្ត នអារម្មណេ សត្ត នអធិបតិយា សត្ត នអនន្តរេ សត្ត នសមនន្តរេ សត្ត នសហជាតេ បញ្ច នអញ្ញមញ្ញេ បញ្ច ននិស្សយេ បញ្ច នឧបនិស្សយេ សត្ត នបុរេជាតេ ឆ នមគ្គេ សត្ត នសម្បយុត្តេ បញ្ច នវិប្បយុត្តេ ចត្តារិ នោអត្ថិយា ចត្តារិ នោនត្ថិយា សត្ត នោវិគតេ សត្ត នោអវិគតេ ចត្តារិ ។

នីវរណវិប្បយុត្តធម៌ក្តី ជាបច្ច័យ នៃនីវរណសម្បយុត្តធម៌ ដោយសហ-ជាតប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ។ នីវរណសម្ប-យុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី ជាបច្ច័យ នៃនីវរណវិប្បយុត្តធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៤៤១ ] ក្នុងនហេតុប្បច្ច័យ មាន៧វារៈ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៤ ។

[ ២២២ ] ហេតុប្បច្ចយា នអារម្មណេ ចត្តារិ ... នអធិបតិយា ចត្តារិ នអនន្តរេ ចត្តារិ នសមនន្តរេ ចត្តារិ នអញ្ញមញ្ញេ ទ្វេ នឧបនិស្សយេ ចត្តារិ នមគ្គេ ចត្តារិ នសម្បយុត្តេ ទ្វេ នវិប្បយុត្តេ ទ្វេ នោនត្ថិយា ចត្តារិ នោវិគតេ ចត្តារិ ។

[ ២២៣ ] នហេតុប្បច្ចយា អារម្មណេ ចត្តារិ ... អធិបតិយា បញ្ច អនុលោមគណនា កាតព្វា អវិគតេ សត្ត ។

នីវរណសម្បយុត្តទុកំ និដ្ឋិតំ ។

# នីវរណនីវរណិយទុកំ

## បដិច្ចវារោ

[ ២២៤ ] នីវរណញ្ចេវ នីវរណិយញ្ច ធម្មំ បដិច្ច នីវរណោ ចេវ នីវរណិយោ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កាមច្ឆន្ទនីវរណំ បដិច្ច ថីនមិទ្ធនីវរណំ ឧទ្ធច្ចនីវរណំ អវិជ្ជានីវរណំ ។ ឃរំ សព្វេ គណនា វិភជិតព្វា ។ នីវរណទុកសទិសា និន្នានាករណា ។

[ ២២២ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ។

[ ២២៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ការរាប់ជាអនុលោម បណ្ឌិតគប្បីធ្វើចុះ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

ចប់ នីវរណសម្បយុត្តទុកៈ ។

# នីវរណនីវរណិយទុកៈ

## បដិច្ចវារៈ

[ ២២៤ ] ធម៌ ជានីវរណៈនិងជានីវរណិយៈ អាស្រ័យ នូវធម៌ជានីវរណៈនិងជានីវរណិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យ នូវកាមច្ឆន្ទនីវរណៈ ។ ការរាប់ទាំងអស់ បណ្ឌិត គប្បីចែក យ៉ាងនេះចុះ ។ ប្រហែលគ្នានឹងនីវរណទុកៈដែរ ឥតមានការធ្វើឲ្យផ្សេងគ្នាឡើយ ។

## បញ្ហាវារោ

[២២៥] នីវរណោ ចេវ នីវរណិយោ ច ធម្មោ នីវរណស្ស ចេវ នីវរណិយស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ នីវរណា ចេវ នីវរណិយា ច ហេតូ សម្បយុត្តកានំ នីវរណានំ ហេតុប្បច្ចយេន បច្ចយោ ។ នីវរណោ ចេវ នីវរណិយោ ច ធម្មោ នីវរណិយស្ស ចេវ នោ ច នីវរណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ នីវរណា ចេវ នីវរណិយា ច ហេតូ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ ។ នីវរណោ ចេវ នីវរណិយោ ច ធម្មោ នីវរណស្ស ចេវ នីវរណិយស្ស ច នីវរណិយស្ស ចេវ នោ ច នីវរណស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ នីវរណា ចេវ នីវរណិយា ច ហេតូ សម្បយុត្តកានំ ខន្ធានំ នីវរណានញ្ច ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ ។ នីវរណិយោ ចេវ នោ ច នីវរណោ ធម្មោ នីវរណិយស្ស ចេវ នោ ច នីវរណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ នីវរណិយា ចេវ នោ ច នីវរណា ហេតូ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ បដិសន្ធិ ។

# បញ្ហាវារៈ

[ ២២៥ ] ធម៌ ជានីវរណៈនិងជានីវរណិយៈ ជាបច្ច័យ នៃធម៌ ជានីវរណៈនិងជានីវរណិយៈ ដោយហេតុប្បច្ច័យ គឺ ពួកហេតុ ជានីវរណៈនិងជានីវរណិយៈ ជាបច្ច័យ នៃពួកសម្បយុត្តកនីវរណៈ ដោយហេតុប្បច្ច័យ ១ ធម៌ ជានីវរណៈនិងជានីវរណិយៈ ជាបច្ច័យ នៃធម៌ ជានីវរណិយៈនិងជានោនីវរណៈ ដោយហេតុប្បច្ច័យ គឺ ពួកហេតុ ជានីវរណៈនិងជានីវរណិយៈ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ១ ធម៌ ជានីវរណៈនិងជានីវរណិយៈ ជាបច្ច័យ នៃធម៌ ជានីវរណៈនិងជានីវរណិយៈផង នៃធម៌ ជានីវរណិយៈនិងជានោនីវរណៈផង ដោយហេតុប្បច្ច័យ គឺ ពួកហេតុ ជានីវរណៈនិងជានីវរណិយៈ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកនីវរណៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ១ ធម៌ ជានីវរណិយៈនិងជានោនីវរណៈ ជាបច្ច័យ នៃធម៌ ជានីវរណិយៈនិងជានោនីវរណៈ ដោយហេតុប្បច្ច័យ គឺ ពួកហេតុ ជានីវរណិយៈនិងជានោនីវរណៈ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ មានបដិសន្ធិ ១

(២២៦) នីវរណោ ចេវ នីវរណិយោ ច ធម្មោ នីវរណស្ស ចេវ នីវរណិយស្ស ច ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ នីវរណេ អារព្ភ នីវរណា ឧប្បជ្ជន្តិ ។ មូលំ បុច្ឆិតព្វំ នីវរណេ អារព្ភ នីរណិយា ចេវ នោចនីវរណា ខន្ធា ឧប្បជ្ជន្តិ ។ មូលំ បុច្ឆិតព្វំ នីវរណេ អារព្ភ នីវរណា ច សម្បយុត្តកា ច ខន្ធា ឧប្បជ្ជន្តិ ។ នីវរណិយោ ចេវ នោចនីវរណោ ធម្មោ នីវរណិយស្ស ចេវ នោចនីវរណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ទានំ ... សីលំ ... ឧបោសថកម្មំ កត្វា តំ បច្ចវេក្ខតិ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចំ ទោមនស្សំ ឧប្បជ្ជតិ បុព្វេ សុចិណ្ណានិ ... ឈានា អរិយា គោត្រភុំ បច្ចវេក្ខន្តិ វោទានំ ... បហីនេ កិលេសេ ... វិក្ខម្ភិតេ កិលេសេ ... បុព្វេ សមុទាចិណ្ណេ ... ចក្ខុំ ... វត្ថុំ ... នីវរណិយេ ចេវ នោចនីវរណេ ខន្ធេ អនិច្ចតោ ... វិបស្សតិ អស្សាទេតិ អភិនន្ទតិ ។ បេ ។ ទោមនស្សំ ...

[ ២២៦ ] ធម៌ ជានីវរណៈនិងជានីវរណិយៈ ជាបច្ច័យ នៃធម៌ ជានីវរណៈនិងជានីវរណិយៈ ដោយអារម្មណប្បច្ច័យ គឺ ពួកនីវរណៈ កើតឡើង ព្រោះប្រារព្ធ នូវពួកនីវរណៈ ។ មូល បណ្ឌិតគប្បីសួរផងចុះ ។ ពួកខន្ធ ជានីវរណិយៈនិងជានោនីវរណៈ កើតឡើង ព្រោះប្រារព្ធ នូវពួកនីវរណៈ ។ មូល បណ្ឌិត គប្បីសួរផងចុះ ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធ នូវពួកនីវរណៈ ។ ធម៌ ជានីវរណិយៈនិងជានោនីវរណៈ ជាបច្ច័យ នៃធម៌ជានីវរណិយៈនិងជានោនីវរណៈ ដោយអារម្មណប្បច្ច័យ គឺ បុគ្គល នូវទាន ... នូវសីល ... ធ្វើ នូវឧបោសថកម្ម ហើយពិចារណា នូវឧបោសថកម្មនោះ ត្រេកអរ រីករាយ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធ នូវហេតុនោះ (នូវពួកអំពើ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ... អំពីឈាន ពួកព្រះអរិយៈ ពិចារណា នូវគោត្រភូ នូវវោទានៈ ... នូវពួកកិលេស ដែលខ្លួនលះបង់ហើយ ... នូវពួកកិលេស ដែលខ្លួនសង្កត់សង្កិនហើយ ... នូវពួកកិលេស ដែលខ្លួនដកឡើងព្រមហើយ ក្នុងកាលមុន ... នូវចក្ខុ ... នូវវត្ថុ ... នូវពួកខន្ធ ជានីវរណិយៈនិងជានោនីវរណៈ ជាមិនទៀង ... ឃើញច្បាស់ ត្រេកអរ រីករាយ ។បេ។ ទោមនស្ស ...

ទិព្វេន ចក្ខុនា ... យាវ អាវជ្ជនា តាវ កាតព្វា ។ នីវរណិយោចេវនោចនីវរណោ ធម្មោ នីវរណស្សចេវនីវរណិយស្សច ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ទានំ ... សីលំ ... ឧបោសថកម្មំ ... បុព្វេ សុចិណ្ណានិ ... ឈានា ... ចក្ខុំ ... វត្ថុំ ... នីវរណិយោចេវនោចនីវរណោ ខន្ធេ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចំ ទោមនស្សំ ឧប្បជ្ជតិ ។ នីវរណិយោចេវនោចនីវរណោ ធម្មោ នីវរណស្សចេវនីវរណិយស្សច នីវរណិយស្សចេវនោចនីវរណស្ស ច ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ទានំ ... សីលំ ... ឧបោសថកម្មំ ... បុព្វេ សុចិណ្ណានិ ... ឈានា ... ចក្ខុំ ... វត្ថុំ ... នីវរណិយោចេវនោចនីវរណោ ខន្ធេ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ នីវរណា ច សម្បយុត្តកា ច ខន្ធា ឧប្បជ្ជន្តិ ។ ឯវំ ឥតរេបិ តីណិ កាតព្វា ។ អារម្មណសទិសា អធិបតិ ។ បុរេជាតម្បិ អារម្មណសទិសំ ។ ឧបនិស្សយេបិ លោកុត្តរំ ន កាតព្វំ ។

ដោយទិព្វចក្ខុ ... ការនឹករំពឹង (មាន) ត្រឹមណា បណ្ឌិត ត្រូវធ្វើត្រឹមណោះ ។ ធម៌ ជានីវរណិយៈនិងជានោនីវរណៈ ជាបច្ច័យ នៃធម៌ ជានីវរណៈនិងជានីវរណិយៈ ដោយអារម្មណប្បច្ច័យ គឺ នូវទាន ... នូវសីល ... នូវឧបោសថកម្ម ...(នូវពួកអំពើ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ... អំពីឈាន ... នូវចក្ខុ ... នូវវត្ថុ ... បុគ្គល ត្រេកអរ រីករាយ ចំពោះពួកខន្ធ ជានីវរណិយៈនិងជានោនីវរណៈ ព្រោះ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធ នូវហេតុនោះ ។ ធម៌ ជានីវរណិយៈនិងជានោនីវរណិយៈ ជាបច្ច័យ នៃធម៌ ជានីវរណៈនិងជានីវរណិយៈផង នៃធម៌ ជានីវរណិយៈនិងជានោនីវរណៈផង ដោយអារម្មណប្បច្ច័យ គឺ នូវទាន ... នូវសីល ... នូវឧបោសថកម្ម ... (នូវពួកអំពើ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ... អំពីឈាន ... នូវចក្ខុ ... នូវវត្ថុ ... បុគ្គល ត្រេកអរ រីករាយ ចំពោះពួកខន្ធ ជានីវរណិយៈនិងជានោនីវរណៈ ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធ នូវហេតុនោះ ។ បណ្ឌិត គប្បីធ្វើ នូវវារៈទាំង ៣ ដទៃ យ៉ាងនេះចុះ ។ អធិបតិប្បច្ច័យ ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ ។ សហជាតប្បច្ច័យ ក៏ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ ។ បណ្ឌិត មិនត្រូវធ្វើ នូវលោកុត្តរៈ ក្នុងឧបនិស្សយប្បច្ច័យឡើយ ។

សង្ខិត្តំ ។ ឯវំ វិត្ថារេតព្វំ ។ យថា នីវរណទុកំ ឯវំ បច្ចវេក្ខិត្វា កាតព្វំ ។

នីវរណនីវរណិយទុកំ និដ្ឋិតំ ។

# នីវរណនីវរណសម្បយុត្តទុកំ

## បដិច្ចវារោ

(២២៧) នីវរណញ្ចេវ នីវរណសម្បយុត្តញ្ច ធម្មំ បដិច្ច នីវរណោ ចេវ នីវរណសម្បយុត្តោ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កាមច្ឆន្ទនីវរណំ បដិច្ច ថីនមិទ្ធនីវរណំ ឧទ្ធច្ចនីវរណំ អវិជ្ជានីវរណំ ចក្កំ សព្វេបិ នីវរណា កាតព្វា ។ នីវរណញ្ចេវ នីវរណសម្បយុត្តញ្ច ធម្មំ បដិច្ច នីវរណសម្បយុត្តោ ចេវ នោ ច នីវរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នីវរណេ បដិច្ច សម្បយុត្តកា ខន្ធា ។ នីវរណញ្ចេវ នីវរណសម្បយុត្តញ្ច ធម្មំ បដិច្ច នីវរណោ ចេវ នីវរណសម្បយុត្តោ ច នីវរណសម្បយុត្តោ ចេវ នោ ច នីវរណោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា កាមច្ឆន្ទនីវរណំ បដិច្ច ថីនមិទ្ធនីវរណំ ឧទ្ធច្ចនីវរណំ អវិជ្ជានីវរណំ សម្បយុត្តកា ច ខន្ធា ចក្កំ ។ នីវរណសម្បយុត្តញ្ចេវ នោ ច នីវរណំ ធម្មំ បដិច្ច

សេចក្តីបំប្រួញ ។ បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនេះចុះ ។ នីវរណ-ទុកៈ យ៉ាងណា បណ្ឌិត គប្បីពិចារណា ហើយធ្វើ យ៉ាងនោះចុះ ។

ចប់ នីវរណនីវរណិយទុកៈ ។

# នីវរណនីវរណសម្បយុត្តទុកៈ

## បដិច្ចវារៈ

(២២៧) ធម៌ ជានីវរណៈនិងជានីវរណសម្បយុត្ត អាស្រ័យ នូវធម៌ ជានីវរណៈនិងជានីវរណសម្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យ នូវកាមច្ឆន្ទនីវរណៈ នីវរណៈទាំងអស់ បណ្ឌិត គប្បីធ្វើឲ្យជាចក្កៈផងចុះ ។ ធម៌ ជានីវរណសម្បយុត្ត និងជានោនីវរណៈ អាស្រ័យ នូវធម៌ ជានីវរណៈនិងជានីវរណសម្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ពួកសម្បយុត្តកក្ខន្ធ អាស្រ័យ នូវពួកនីវរណៈ ។ ធម៌ ជានីវរណនិងជានីវរណៈសម្បយុត្តក៏ ជានីវរណ-សម្បយុត្តនិងជានោនីវរណៈក៏ អាស្រ័យ នូវធម៌ ជានីវរណៈនិងជានីវរណសម្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ថីន-មិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ អវិជ្ជានីវរណៈ និងពួកសម្បយុត្តកក្ខន្ធ អាស្រ័យ នូវកាមច្ឆន្ទនីវរណៈ បណ្ឌិត គប្បីធ្វើ ឲ្យជាចក្កៈផងចុះ ។ ធម៌ ជានីវរណសម្បយុត្តនិងជានោនីវរណៈ អាស្រ័យ នូវធម៌

នីវរណសម្បយុត្តោ ចេវ នោ ច នីវរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នីវរណសម្បយុត្តញ្ចេវ នោ ច នីវរណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... ។ នីវរណសម្បយុត្តញ្ចេវ នោ ច នីវរណំ ធម្មំ បដិច្ច នីវរណោ ចេវ នីវរណសម្បយុត្តោ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នីវរណសម្បយុត្តេ ចេវ នោ ច នីវរណេ ខន្ធេ បដិច្ច នីវរណា ។ នីវរណសម្បយុត្តញ្ចេវ នោ ច នីវរណំ ធម្មំ បដិច្ច នីវរណោ ចេវ នីវរណសម្បយុត្តោ ច នីវរណសម្បយុត្តោ ចេវ នោ ច នីវរណោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា នីវរណសម្បយុត្តញ្ចេវ នោ ច នីវរណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា នីវរណា ច ទ្វេ ខន្ធេ ... ។ នីវរណញ្ចេវ នីវរណសម្បយុត្តញ្ច នីវរណសម្បយុត្តញ្ចេវ នោ ច នីវរណញ្ច ធម្មំ បដិច្ច នីវរណោ ចេវ នីវរណសម្បយុត្តោ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កាមច្ឆន្ទនីវរណញ្ច សម្បយុត្តកេ ច ខន្ធេ បដិច្ច ថីនមិទ្ធនីវរណំ ឧទ្ធច្ចនីវរណំ អវិជ្ជានីវរណំ ចក្កំ ។ នីវរណញ្ចេវ នីវរណសម្បយុត្តញ្ច នីវរណសម្បយុត្តញ្ចេវ នោ ច នីវរណញ្ច ធម្មំ បដិច្ច នីវរណសម្បយុត្តោ ចេវ នោ ច នីវរណោ ធម្មោ ឧប្បជ្ជតិ

ជានីវរណសម្បយុត្តនិងជានោនីវរណៈ ទើបកើតឡើង ព្រោះហេតុប្ប-
ច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវខន្ធ ១ ជានីវរណសម្បយុត្តនិងជានោនី-
វរណៈ នូវខន្ធ ២ ... ។ ធម៌ ជានីវរណៈនិងជានីវរណសម្បយុត្ត
អាស្រ័យ នូវធម៌ ជានីវរណសម្បយុត្តនិងជានោនីវរណៈ ទើបកើត
ឡើង ព្រោះហេតុប្បច្ច័យ គឺ ពួកនីវរណៈ អាស្រ័យ នូវពួកខន្ធ
ជានីវរណសម្បយុត្តនិងជានោនីវរណៈ ។ ធម៌ ជានីវរណៈនិងជានីវ-
រណសម្បយុត្តក្តី ជានីវរណសម្បយុត្តនិងជានោនីវរណៈក្តី អាស្រ័យ
នូវធម៌ ជានីវរណសម្បយុត្តនិងជានោនីវរណៈ ទើបកើតឡើង ព្រោះ
ហេតុប្បច្ច័យ គឺ ខន្ធ ៣ ផង ពួកនីវរណៈផង អាស្រ័យ នូវខន្ធ ១
ជានីវរណសម្បយុត្តនិងជានោនីវរណៈ នូវខន្ធ ២ ... ។ ធម៌ ជា
នីវរណៈនិងជានីវរណសម្បយុត្ត អាស្រ័យ នូវធម៌ ជានីវរណៈនិងជា
នីវរណសម្បយុត្តផង ជានីវរណសម្បយុត្តនិងជានោនីវរណៈផង ទើប
កើតឡើង ព្រោះហេតុប្បច្ច័យ គឺ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ អវិជ្ជា-
នីវរណៈ អាស្រ័យ នូវកាមច្ឆន្ទនីវរណៈផង នូវពួកសម្បយុត្តកខន្ធផង
បណ្ឌិត (គប្បីធ្វើ) ឲ្យជាបក្ខៈផងចុះ ។ ធម៌ ជានីវរណសម្បយុត្ត
និងជានោនីវរណៈ អាស្រ័យ នូវធម៌ ជានីវរណៈនិងជានីវរណសម្ប-
យុត្តផង ជានីវរណសម្បយុត្តនិងជានោនីវរណៈផង ទើបកើតឡើង

ហេតុប្បច្ចយា នីវរណសម្បយុត្តញ្ចេវ នោចនីវរណំ ឯកំ ខន្ធញ្ច នីវរណេ ច បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... ។ នីវរណញ្ចេវ នីវរណសម្បយុត្តញ្ច នីវរណសម្បយុត្តញ្ចេវ នោចនីវរណញ្ច ធម្មំ បដិច្ច នីវរណោចេវ នីវរណសម្បយុត្តោ ច នីវរណសម្បយុត្តោចេវ នោចនីវរណោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា នីវរណសម្បយុត្តញ្ចេវ នោចនីវរណំ ឯកំ ខន្ធញ្ច កាមច្ឆន្ទនីវរណញ្ច បដិច្ច តយោ ខន្ធា ថីនមិទ្ធនីវរណំ ឧទ្ធច្ចនីវរណំ អវិជ្ជានីវរណំ ទ្វេ ខន្ធេ ... ចក្កំ ។ សង្ខិត្តំ ។

(២២៨) ហេតុយា នវ អារម្មណេ នវ អធិបតិយា នវ សព្វត្ថ នវ កម្មេ នវ អាហារេ នវ អវិគតេ នវ ។

(២២៩) នីវរណញ្ចេវ នីវរណសម្បយុត្តញ្ច ធម្មំ បដិច្ច នីវរណោចេវ នីវរណសម្បយុត្តោ ច ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា វិចិកិច្ឆានីវរណំ បដិច្ច អវិជ្ជានីវរណំ ឧទ្ធច្ចនីវរណំ បដិច្ច អវិជ្ជានីវរណំ ។ នីវរណសម្បយុត្តញ្ចេវ នោចនីវរណំ ធម្មំ បដិច្ច នីវរណោចេវ នីវរណសម្បយុត្តោ ច ធម្មោ ឧប្បជ្ជតិ

ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវខន្ធ ១ ជានីវរណសម្ប-យុត្តនិងជានោនីវរណៈផង នូវពួកនីវរណៈផង នូវខន្ធ ២ ... ។ ធម៌ ជានីវរណៈនិងជានីវរណសម្បយុត្តក៏ ជានីវរណសម្បយុត្តនិងជានោនីវរណៈក្តី អាស្រ័យ នូវធម៌ ជានីវរណៈនិងជានីវរណសម្បយុត្តផង ជានីវរណសម្បយុត្តនិងជានោនីវរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ជាថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងជាអវិជ្ជា-នីវរណៈ អាស្រ័យ នូវខន្ធ ១ ជានីវរណសម្បយុត្តនិងជានោនីវរណៈផង នូវកាមច្ឆន្ទនីវរណៈផង នូវខន្ធ ២ ... បណ្ឌិត (គប្បីធ្វើ) ឲ្យជាចក្កៈផងចុះ ។ សេចក្តីបំប្រួញ ។

( ២២៨ ) ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

( ២២៩ ) ធម៌ ជានីវរណៈនិងជានីវរណសម្បយុត្ត អាស្រ័យ នូវធម៌ ជានីវរណៈនិងជានីវរណសម្បយុត្ត ទើបកើតឡើង ព្រោះនហេតុ-ប្បច្ច័យ គឺ អវិជ្ជានីវរណៈ អាស្រ័យ នូវវិចិកិច្ឆានីវរណៈ អវិជ្ជានីវរណៈ អាស្រ័យ នូវឧទ្ធច្ចនីវរណៈ ។ ធម៌ ជានីវរណៈនិងជានីវរណសម្បយុត្ត អាស្រ័យ នូវធម៌ ជានីវរណសម្បយុត្តនិងជានោនីវរណៈ ទើបកើតឡើង

នហេតុប្បច្ចយា វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ បដិច្ច អវិជ្ជានីវរណំ ។ នីវរណញ្ចេវ នីវរណសម្បយុត្តញ្ច នីវរណសម្បយុត្តញ្ចេវ នោ ច នីវរណញ្ច ធម្មំ បដិច្ច នីវរណោ ចេវ នីវរណសម្បយុត្តោ ច ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា វិចិកិច្ឆានីវរណញ្ច សម្បយុត្តកេ ច ខន្ធេ បដិច្ច អវិជ្ជានីវរណំ ឧទ្ធច្ចនីវរណញ្ច សម្បយុត្តកេ ច ខន្ធេ បដិច្ច អវិជ្ជានីវរណំ ។ សង្ខិត្តំ ។

(២៣០) នហេតុយា តីណិ នអធិបតិយា នវ នបុរេជាតេ នវ នបច្ឆាជាតេ នវ នអាសេវនេ នវ នកម្មេ តីណិ នវិបាកេ នវ នវិប្បយុត្តេ នវ ។

(២៣១) ហេតុប្បច្ចយា នអធិបតិយា នវ ។ សង្ខិត្តំ ។ ... នវិប្បយុត្តេ នវ ។

(២៣២) នហេតុប្បច្ចយា អារម្មណេ តីណិ ... អនន្តរេ តីណិ សមនន្តរេ តីណិ សហជាតេ តីណិ មគ្គេ តីណិ អវិគតេ តីណិ ។

ព្រោះនហេតុប្បច្ច័យ គឺ អវិជ្ជានីវរណៈ អាស្រ័យ នូវពួកខន្ធ ដែលប្រកប ដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ ធម៌ ជានីវរណៈនិងជានីវរណសម្បយុត្ត អាស្រ័យ នូវធម៌ ជានីវរណៈនិងជានីវរណសម្បយុត្តផង ជានីវរណសម្បយុត្តនិងជានោនីវរណៈផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ អវិជ្ជានីវរណៈ អាស្រ័យ នូវវិចិកិច្ឆានីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង អវិជ្ជានីវរណៈ អាស្រ័យ នូវឧទ្ធច្ចនីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង ។ សេចក្តីបំប្រួញ ។

[ ២៣០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ២៣១ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។ សេចក្តីបំប្រួញ ។ . . . ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ២៣២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ . . . ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ឯវំ សហជាតវារេបិ បច្ចយវារេបិ និស្សយវារេបិ សំសដ្ឋវារេបិ សម្បយុត្តវារេបិ បដិច្ចវារសទិសា និដ្ឋាតព្វា ។

## បញ្ហាវារោ

( ២៣៣ ) នីវរណោ ចេវ នីវរណសម្បយុត្តោ ច ធម្មោ នីវរណស្ស ចេវ នីវរណសម្បយុត្តស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ នីវរណោ ចេវ នីវរណសម្បយុត្តោ ច ហេតុ សម្បយុត្តកានំ នីវរណានំ ហេតុប្បច្ចយេន បច្ចយោ ។ នីវរណោ ចេវ នីវរណសម្បយុត្តោ ច ធម្មោ នីវរណសម្បយុត្តស្ស ចេវ នោ ច នីវរណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ នីវរណោ ចេវ នីវរណសម្បយុត្តោ ច ហេតុ នីវរណសម្បយុត្តានំ ខន្ធានំ ហេតុប្បច្ចយេន បច្ចយោ ។ នីវរណោ ចេវ នីវរណសម្បយុត្តោ ច ធម្មោ នីវរណស្ស ចេវ នីវរណសម្បយុត្តស្ស ច នីវរណសម្បយុត្តស្ស ចេវ នោ ច នីវរណស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ នីវរណោ ចេវ នីវរណសម្បយុត្តោ ច ហេតុ សម្បយុត្តកានំ ខន្ធានំ នីវរណានញ្ច ហេតុប្បច្ចយេន បច្ចយោ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈ យ៉ាងនេះដែរ មិនមានការធ្វើឲ្យផ្សេងគ្នាទេ ។

# បញ្ហាវារ:

